ហត្ថា
Hattha Bank

Subsidiary of krungsri bank

A member of MUFG, a global financial group

# របាយការណ៍ ត្រីមាសទី៣

ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | ត្រីមាសទី៣ ឆ្នាំ២០២១ | ២០២០ | ២០១៩ |
|---|---|---|---|
| ទ្រព្យសកម្មសរុប (លានរៀល) | ៧ ៤៨១ ០១៦ | ៦ ៣៧០ ៨៥០ | ៤ ៩៩៩ ៣២៣ |
| បំណុលសរុប (លានរៀល) | ៦ ១៧៨ ១៨៤ | ៥ ៣២០ ៦២៥ | ៤ ១៩១ ០០៦ |
| មូលធនសរុប (លានរៀល) | ១ ៣០២ ៨៣២ | ១ ០៥០ ២២៥ | ៨០៨ ៣១៧ |
| **លទ្ធផលហិរញ្ញវត្ថុ** | **ត្រីមាសទី៣ ឆ្នាំ២០២១** | **ត្រីមាសទី៣ ឆ្នាំ២០២០** | **ត្រីមាសទី៣ ឆ្នាំ២០១៩** |
| ចំណូលសរុប (លានរៀល) | ២៣៦ ០៣៨ | ១៨១ ៦១៩ | ១៥៥ ៤៤៧ |
| ចំណេញ/(ខាត)មុនបង់ពន្ធ (លានរៀល) | ១២២ ២៦៣ | ៦៥ ៨៤១ | ៤០ ៣៦០ |
| ចំណេញ/(ខាត)សុទ្ធក្នុងការិយបរិច្ឆេទ(លានរៀល) | ៩៧ ៨៦៦ | ៥២ ៦២៧ | ៣២ ២៥៤ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ (លានរៀល) | ១០០ ៣២៨ | ៥៤ ៥០៣ | ៣៤ ៦៥២ |
| **អនុបាតហិរញ្ញវត្ថុ** | **ត្រីមាសទី៣ ឆ្នាំ២០២១** | **២០២០** | **២០១៩** |
| អនុបាតសាធនភាព (ភាគរយ) | ១៨,៣ | ១៧,៨ | ១៩,៤ |
| អនុបាតបំណុលធៀបនឹងមូលធន (ភាគរយ) | ៤៧៤ | ៥០៧ | ៥១៨ |
| អនុបាតសន្ទនីយភាព (ភាគរយ) | ១៥០,៩ | ១៣១,០ | ១១៣,៩ |
| អនុបាតឥណទានមិនដំណើរការ[1] (ភាគរយ) | ១,៥២ | ១,៣១ | ០,៣០ |
| អនុបាតបញ្ញើឥណទាន (ភាគរយ) | ៥៦,៨ | ៥៩,៩ | ៥៧,០ |
| | **ត្រីមាសទី៣ ២០២១** | **ត្រីមាសទី៣ ឆ្នាំ២០២០** | **ត្រីមាសទី៣ ឆ្នាំ២០១៩** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម (ភាគរយ) | ១,៣១ | ០,៩១ | ០,៦១ |
| អនុបាតចំណេញធៀបនឹងមូលធន (ភាគរយ) | ៧,៥១ | ៥,១៤ | ៣,៤៦ |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ភាគរយ) | ២៣៦ | ១៩០ | ១៥៧ |



[1] និយមន័យរបស់ធនាគារជាតិនៃកម្ពុជា

# គ្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប






# សមាសភាពក្រុមប្រឹក្សាភិបាល



លោក Dan HARSONO
ប្រធានក្រុមប្រឹក្សាភិបាល



លោកឧកញ៉ា ហួត អៀងតុង
អភិបាល



កញ្ញា Duangdao WONGPANITKRIT
អភិបាល



លោក Pairote CHEUNKRUT
អភិបាល



លោក Chandrashekar S.K.
អភិបាល



លោក Wanchairabin JITWATTANATAM
អភិបាល



លោក ឡូញ ហៃ
អភិបាលឯករាជ្យ



លោក ឌី ដាវុឌ្ឍ
អភិបាលឯករាជ្យ



លោក ប៉ាក សេរីវឌ្ឍនា
អភិបាលឯករាជ្យ

## សេចក្ដីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ប្រទេសកម្ពុជា កំពុងស្ថិតក្នុងមាគ៌ានៃការងើបឡើងវិញ ដ៏ល្អនៃកំណើនសេដ្ឋកិច្ចដែលជាលទ្ធផលនៃវិធានការណ៍យ៉ាងសកម្មជាច្រើនពីរាជរដ្ឋាភិបាល និងអាជ្ញាធរមានសមត្ថកិច្ចរួមទាំង ធនាគារជាតិនៃកម្ពុជាដើម្បីគ្រប់គ្រងស្ថានការណ៍ កូវីដ១៩។ យុទ្ធនាការនៃការចាក់វ៉ាក់សាំងប្រកបដោយប្រសិទ្ធភាព ដែលបានធ្វើឱ្យប្រទេសកម្ពុជាមានអត្រានៃការចាក់វ៉ាក់សាំងបានច្រើនបំផុតនៅក្នុងអាស៊ាន ដើម្បីទប់ស្កាត់ជំងឺកូវីដ១៩ ប្រកបដោយប្រសិទ្ធភាព។ នៅក្នុងត្រីមាសទី៣ នៃឆ្នាំ ២០២១ យើងបានមើលឃើញការកើនឡើងនូវសកម្មភាពសេដ្ឋកិច្ចនៅក្នុងស្រុក ដោយបានដើរស្របទៅតាមដំណាក់កាលរបស់ពិភពលោកផងដែរ។ ដំណើរការអាជីវកម្មរបស់ធនាគារ ហត្ថា ម.ក មានការកើនឡើងយ៉ាងខ្លាំងនៅក្នុងត្រីមាសនេះ។

បើធ្វើការប្រៀបធៀបទៅនឹងត្រីមាសទី២ ផលប័ត្រប្រាក់កម្ចីបានកើនឡើងដល់ ១ ៥២៤ លានដុល្លារអាមេរិក កើនឡើង ៧,៥% ។ ផលប័ត្រប្រាក់បញ្ញើសន្សំរបស់យើងមានចំនួន ៨៦៦ លានដុល្លារអាមេរិក ។ ឥណទានមិនដំណើរការ បានធ្វើឱ្យប្រសើរឡើងត្រឹម ០,៧៨% បើធៀបទៅនឹងត្រីមាសទី២ គឺ១,២១% ដោយសារតែការត្រួតពិនិត្យ និងការគ្រប់គ្រងផលប័ត្រឥណទានប្រកបដោយប្រសិទ្ធភាព។ រីឯអនុបាតគ្របខ័ណ្ឌសន្ទនីយភាព LCR មានចំនួន ១៥១% ខ្ពស់ជាងការកំណត់របស់និយ័តករដែលកំណត់ត្រឹមតែ ១០០%។ សរុបជារួមមក ស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ ហត្ថា ម.ក នៅត្រីមាសទី៣បានបញ្ចប់ជាមួយនឹងលទ្ធផលគួរជាទីពេញចិត្ត។

ធនាគារ ហត្ថា ម.ក បានបន្តកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈររបស់ខ្លួនក្នុងការគាំទ្រអតិថិជនដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ១៩។ នៅដំណាច់ត្រីមាសនេះ ធនាគារ ហត្ថា ម.ក បានផ្ដល់ការគាំទ្រដល់អតិថិជនតាមរយៈការរៀបចំឥណទានសារឡើងវិញ មានចំនួនជាង ២៨ ០០០ គណនី ស្មើនឹងចំនួនទឹកប្រាក់ប្រហែលជិត ២៨៣ លានដុល្លារអាមេរិក ឬ ១៨,៥% នៃផលប័ត្រប្រាក់កម្ចីសរុបរបស់ខ្លួន។ ធនាគារ បានបន្តវិធានការបង្ការជាចាំបាច់ ដើម្បីធានាសុវត្ថិភាពដល់អតិថិជន ក៏ដូចជាបុគ្គលិករបស់យើង។ វិធានការទាំងនេះរួមមាន ការបំបែកកន្លែងធ្វើការ ការប្រើឧបករណ៍ធ្វើតេស្តរហ័សសម្រាប់ពិនិត្យបុគ្គលិក និងគោលនយោបាយស្ដីពីការធ្វើការងារពីផ្ទះ។

លើសពីនេះ ខ្ញុំរីករាយក្នុងការធ្វើបច្ចុប្បន្នភាពពីវឌ្ឍនភាពជាច្រើន ដែលបានកើតឡើងក្នុងអំឡុងពេលនេះ។ សេវាប្ដូរប្រាក់ ឥឡូវនេះមាននៅសាខាធនាគារ ហត្ថា ម.ក ក្នុងរាជធានីភ្នំពេញ និងតាមខេត្តជិតៗ ដើម្បីសម្រួលដល់ប្រតិបត្តិការរបស់អតិថិជនក្នុងអត្រាប្ដូរប្រាក់ដ៏គួរឱ្យទាក់ទាញ។ ចាប់ពីខែតុលា តទៅ ធនាគារ ហត្ថា ម.ក បានណែនាំសេវាកម្មផ្ទេរប្រាក់ពីប្រទេសកម្ពុជាទៅប្រទេសថៃ នៅគ្រប់សាខាធនាគារក្រុងស្រី ដែលបើកឱ្យដំណើរការតាមបច្ចេកវិទ្យាកម្មសិទ្ធិរបស់យើង។ នេះគឺជាសេវាផ្ញើប្រាក់ទាន់ពេលវេលាពិតប្រាកដមួយ ដែលមានប្រសិទ្ធភាពបំផុតនៅក្នុងប្រទេស។ កាលពីដើមខែកក្កដា ធនាគារក៏បានចាប់ផ្តើមសាងសង់ទីស្នាក់ការកណ្តាលថ្មីរបស់ខ្លួនគឺឈ្មោះថា Hattha Bank Tower ដែលមានទីតាំងនៅតាមបណ្តោយមហាវិថីសម្តេចតេជោ ហ៊ុន សែន ជាតំបន់អភិវឌ្ឍន៍សេដ្ឋកិច្ចថ្មី ដែលមានចំនួនអាជីវកម្ម និងការវិនិយោគកើនឡើងយ៉ាងឆាប់រហ័ស។ ការសាងសង់ និងការរចនាអគារនេះឡើង មានគោលបំណងដើម្បីសម្រេចបានវិញ្ញាបនប័ត្រ BCA Green Mark សម្រាប់អនុវត្តតាមបេសកកម្មប្រកបដោយនិរន្តរភាពរបស់យើង។

ធនាគារ ហត្ថា ម.ក បានបោះផ្សាយលក់សញ្ញាបណ្ណសាជីវកម្មដំបូងគេបំផុតនៅកម្ពុជាក្នុងឆ្នាំ២០១៨ ក្រោមឈ្មោះមុនរបស់ខ្លួន “ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ លីមីតធីត” នឹងឈានដល់កាលកំណត់នៅក្នុងខែវិច្ឆិកានេះ។

យើងបានធ្វើដំណើរមកឆ្ងាយហើយ បើគិតពីចំណុចចាប់ផ្តើមនោះ ដែលយើងជាអ្នកត្រួសត្រាយផ្លូវទៅកាន់ផ្សារមូលធនបំណុលរបស់ប្រទេសកម្ពុជា។ ខ្ញុំសូមឆ្លៀតយកឱកាសនេះ ដើម្បីថ្លែងអំណរគុណចំពោះការគាំទ្រ និងការជឿទុកចិត្តដ៏ខ្លាំងខ្លាពីសំណាក់និយ័តករ វិនិយោគិន អតិថិជន និងអ្នកទាំងអស់គ្នានៅធនាគារ ហត្ថា ម.ក របស់យើង។

ថ្វីបើជំងឺរាតត្បាតជាសកលនៅសេសសល់ក៏ដោយ ក៏យើងមើលឃើញពន្លឺកាន់តែច្រើន និងក្តីសង្ឃឹមសម្រាប់មនុស្សគ្រប់គ្នាក្នុងស្ថានភាពធម្មតាថ្មី។ ធនាគារ ហត្ថា ម.ក នឹងបន្តរីកលូតលាស់ខាងអាជីវកម្មធនាគារ និងពង្រីកសេវាកម្មរបស់ខ្លួន មិនត្រឹមតែអតិថិជនកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអ្នកវិនិយោគ ដែលកំពុងស្វែងរកពាណិជ្ជកម្ម ឬវិនិយោគនៅក្នុងប្រទេសផងដែរ។ ខ្ញុំសូមជូនពរឱ្យអ្នកទាំងអស់គ្នាមានសុវត្ថិភាព និងរឹងមាំនៅក្នុងស្ថានភាពធម្មតាថ្មី និងលើសពីនេះទៀត។

កាលបរិច្ឆេទៈ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០២១
ហត្ថលេខា និង ត្រា

លោក Dan HARSONO
ប្រធានក្រុមប្រឹក្សាភិបាល

# សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក

រហូតដល់ត្រីមាសទី៣ ឆ្នាំ២០២១នេះ ធនាគារ ហត្ថា ម.ក បានបន្តភាពខ្លាំងរបស់ខ្លួនក្នុងការពង្រីកវិសាលភាពអាជីវកម្ម យ៉ាងទូលំទូលាយ និងទទួលបានជោគជ័យគួរជាទីមោទនភាព ដែលជាកត្តាមួយជំរុញ ឱ្យធនាគារ ហត្ថា ម.ក បាននឹងកំពុងក្លាយទៅជាធនាគារពាណិជ្ជមួយឈានមុខក្នុងប្រទេសកម្ពុជា ហើយក៏ជាផ្នែកមួយដ៏សំខាន់ក្នុងការទ្រទ្រង់ដល់ការរីកចម្រើនដល់សេដ្ឋកិច្ចជាតិកម្ពុជា។ ដូច្នេះហើយ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា បុគ្គលិករបស់ធនាគារ ហត្ថា ម.ក គ្រប់ជាន់ថ្នាក់នឹងខិតខំប្រឹងប្រែងបន្តពង្រឹងទំនាក់ទំនងល្អៗជាមួយអតិថិជន និងដៃគូអាជីវកម្មរបស់យើងដើម្បីបង្កើនឧត្តមភាពបម្រើសេវាហិរញ្ញវត្ថុ ឱ្យកាន់តែសាមញ្ញ ងាយស្រួល រហ័សទាន់ចិត្ត ដើម្បីលើកកម្ពស់ដល់ប្រសិទ្ធភាពប្រតិបត្តិការ និងរក្សាសុវត្ថិភាពជូនអតិថិជន ព្រមទាំងទប់ស្កាត់ហានិភ័យនានាយ៉ាងមានប្រសិទ្ធភាពខ្ពស់។

ប្រសិនគិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ធនាគារ ហត្ថា ម.ក បានទទួលលទ្ធផលល្អប្រសើរដូចខាងក្រោម៖

- សមតុល្យប្រាក់កម្ចីលើសផែនការ ១១,៨២%
- ប្រាក់បញ្ញើសន្សំលើសផែនការ ៥,៥៤%
- ឥណទានមិនដំណើរការគឺ ០,៧៨%ល្អប្រសើរជាងផែនការចំនួន ០,៩២%
- ប្រាក់ចំណូលសុទ្ធសរុបលើសផែនការ ៥៨,៤១%
- យើងបានណែនាំផលិតផលថ្មីៗរបស់ធនាគារ ហត្ថា ម.ក ដោយបានដាក់ឱ្យដំណើរការសេវាកម្មផ្ទេរប្រាក់ពីប្រទេសកម្ពុជាទៅកាន់ប្រទេសថៃ និងដំណើរការសាកល្បង សេវាកម្មប្តូរប្រាក់ជាដើម នៅក្នុងត្រីមាសទី៣ផងដែរ។

សម្រាប់ត្រីមាសទី ៤ យើងសង្កេតឃើញថា ផលប៉ះពាល់នៃការរីករាតត្បាតនៃជំងឺកូវីដ១៩ គឺមានសភាពធូរស្រាល ហើយរាជរដ្ឋាភិបាលនឹងគ្រោងបើកដំណើរការនៃវិស័យសំខាន់ៗ ដើម្បីជំរុញសេដ្ឋកិច្ចប្រទេសកម្ពុជាឱ្យមានកំណើនឡើងវិញ ដែលនេះគឺសញ្ញាណដ៏ល្អសម្រាប់ប្រតិបត្តិករហិរញ្ញវត្ថុទាំងអស់ក៏ដូចជា ធនាគារ ហត្ថា ម.ក ផងដែរ ហេតុនេះខ្ញុំសូមលើកទឹកចិត្តគណៈគ្រប់គ្រង និងបុគ្គលិកគ្រប់ជាន់ថ្នាក់បន្តជំរុញប្រតិបត្តិការអាជីវកម្មរបស់យើងឱ្យបានខ្លាំងខ្លាបំផុត ដើម្បីសម្រេចបាននូវគោលដៅអាជីវកម្មដែលបានកំណត់ទុក។ លើសពីនេះ យើងត្រូវបន្តគោរព និងអនុវត្តវិធានការការពារនានារបស់ក្រសួង សុខាភិបាល និងរាជរដ្ឋាភិបាលកម្ពុជាឱ្យបានតឹងរឹងបំផុត ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ជាពិសេសការពារសុខភាព និងសុវត្ថិភាពទាំងអស់គ្នា។

ជាចុងក្រោយ ខ្ញុំសូមជូនពរដល់គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ ឱ្យមានសុខភាពល្អ សំណាងល្អ រកទទួលទានមានបាន និងសុខដុមរមនានៅក្នុងគ្រួសារជៀសផុតពីជំងឺកូវីដ១៩។

កាលបរិច្ឆេទ៖ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០២១
ហត្ថលេខា

លោកឧកញ៉ា ហួត អៀងតុង
ប្រធានអគ្គនាយក

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ....................................................................................................i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប....................................................................................ii

សមាសភាពក្រុមប្រឹក្សាភិបាល..............................................................................................iii

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល................................................................................iv

សេចក្តីថ្លែងរបស់ប្រធានអគ្គនាយក.........................................................................................vi

ផ្នែកទី ១ ៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីមូលបត្រ ........................................................ ១

ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ .................................................................... ១

ខ- លក្ខណៈនៃធុរកិច្ច ................................................................................................... ១

គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ........................................ ២

ផ្នែកទី ២ ៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ................................................................. ៣

ក- លទ្ធផលប្រតិបត្តិការធុរកិច្ច......................................................................................... ៣

ខ- រចនាសម្ព័ន្ធចំណូល ................................................................................................ ៤

ផ្នែកទី ៣ ៖ របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ .................................៥

ផ្នែកទី ៤ ៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង.............................................................៦

ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ.......................................................................................... ៦

ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ........................................................................ ៦

គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល.................................................................... ៦

ឃ-ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ.................................................. ៦

ង- ផលប៉ះពាល់នៃអតិផរណា.............................................................................................. ៧

ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ..................................... ៧

## ផ្នែកទី ១ ៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីមូលបត្រ

### ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | ធនាគារ ហត្ថា ម.ក |
| ឈ្មោះជាអក្សរឡាតាំង | Hattha Bank Plc. |
| កូដស្តង់ដារ | KH20000718B4 |
| អាសយដ្ឋាន | អគារលេខ ៦០៦ ផ្លូវ២៧១ ភូមិសន្សំកុសល ៣ សង្កាត់បឹងទំពន់ ទី១ ខណ្ឌមានជ័យ រាជធានីភ្នំពេញ |
| លេខទូរស័ព្ទ | ០២៣ ៩៩៤ ៣០៤ |
| គេហទំព័រ | www.hatthabank.com |
| អ៊ីម៉ែល | info@hatthabank.com |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៩៣៩៥ (ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០១) |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ធ-៥៦ ចេញដោយ: ធនាគារជាតិនៃកម្ពុជាកាលបរិច្ឆេទ: ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ ១៦៥/១៨គ.ម.ក. កាលបរិច្ឆេទ: ថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៨ |
| តំណាងធនាគារ ហត្ថា ម.ក ដោយ | លោកឧកញ៉ា ហួត អៀងតុង |

### ខ- លក្ខណៈនៃធុរកិច្ច

ធនាគារ ហត្ថា ម.ក គឺជាធនាគារមួយក្នុងចំណោមធនាគារឈានមុខផ្សេងទៀតនៅកម្ពុជា ដែលទទួលបានអាជ្ញាបណ្ណធ្វើប្រតិបត្តិការធនាគារពាណិជ្ជពី ធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្ម ចាប់ពីថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០២០។ ជាមួយបទពិសោធន៍ក្នុងការបម្រើសេវាហិរញ្ញវត្ថុទៅកាន់ប្រជាជនកម្ពុជាអស់រយៈពេលជិត ៣០ឆ្នាំ ក្រោយការផ្លាស់ប្តូរមុខមាត់ថ្មីរបស់ខ្លួន ធនាគារ ហត្ថា ម.ក បានកែលម្អ និងដាក់ឱ្យប្រើប្រាស់បន្ថែមនូវសេវាកម្មហិរញ្ញវត្ថុជាច្រើនផ្សេងទៀតក្នុងនោះមានដូចជា៖ ការធ្វើឱ្យកាន់តែប្រសើរឡើងនូវសេវាធនាគារចល័ត (Hattha Mobile) ដាក់ឱ្យប្រើប្រាស់នូវសេវាផ្ទេរប្រាក់ឆ្លងធនាគារ សេវាឥណទានវិបារូបន៍ សេវាបញ្ញើសន្សំ (គណនីចរន្ត គណនីHYSA Flexi និង HYSA Corporate) និងការត្រៀមខ្លួនក្នុងការផ្តល់ជូនសេវាធនាគារថ្មីៗផ្សេងទៀត បន្ថែមលើសេវាដែលមានស្រាប់ដូចជា៖ សេវាឥណទាន សេវាប្រាក់បញ្ញើសន្សំ សេវាផ្ទេរប្រាក់ក្នុងស្រុក សេវាអេធីអឹម សេវាបើកប្រាក់បៀវត្ស សេវាទូទាត់វេហ៍ស សេវាប្រមូលសាច់ប្រាក់ និងជាអ្នកណែនាំលក់សេវាធានារ៉ាប់រងផងដែរ។

គិតត្រឹម ខែ កញ្ញា ឆ្នាំ ២០២១ សមតុល្យប្រាក់បញ្ញើសន្សំ របស់ ធនាគារ ហត្ថា ម.ក មានចំនួនជាង ៨៦៦ លានដុល្លារអាមេរិក ជាមួយនឹងចំនួនអតិថិជនប្រាក់បញ្ញើសន្សំ ២៨៤ ១៦៩ នាក់ និងផលប័ត្រឥណទានសរុបមានចំនួន

ប្រមាណ ១ ៥២៤ លានដុល្លារអាមេរិក ដែលបម្រើអតិថិជន ចំនួន ១៩៥ ២៩១ នាក់ តាមរយៈសាខាចំនួន ១៧៧ និង ម៉ាស៊ីនអេធីអឹមចំនួន ១៣៧ទីតាំង នៅទូទាំងប្រទេស។

ធនាគារ ហត្ថា ម.ក គឺជាបុត្រសម្ព័ន្ធរបស់ ធនាគារ ក្រុងស្រី។ ធនាគារ ក្រុងស្រី (ធនាគារ អាយុធ្យា ម.ក និង ក្រុមហ៊ុនជាបុត្រសម្ព័ន្ធ) គឺជាសម្ព័ន្ធហិរញ្ញវត្ថុធំជាងគេលំដាប់ទី៥ នៅក្នុងព្រះរាជាណាចក្រថៃ ដោយយោងលើទំហំ ទ្រព្យសកម្ម ផលប័ត្រឥណទាន និងប្រាក់បញ្ញើសន្សំ និងជាធនាគារមួយក្នុងចំណោមធនាគារ D-SIBs ចំនួនប្រាំ ដែល បានធ្វើប្រតិបត្តិការអាជីវកម្មជូនអតិថិជនរបស់ខ្លួនអស់រយៈពេល ៧៦ ឆ្នាំ មកហើយនៅក្នុងព្រះរាជាណាចក្រថៃ។ ធនាគារ ក្រុងស្រី គឺជាសមាជិកយុទ្ធសាស្ត្ររបស់សម្ព័ន្ធហិរញ្ញវត្ថុ MUFG ដែលជាសម្ព័ន្ធហិរញ្ញវត្ថុធំជាងគេបង្អស់នៅ ជប៉ុន ក៏ដូចជាសម្ព័ន្ធហិរញ្ញវត្ថុដ៏ធំមួយក្នុងចំណោមសម្ព័ន្ធហិរញ្ញវត្ថុធំៗផ្សេងទៀតនៅលើពិភពលោក។

### គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

វាគឺជាដំណឹងដ៏រីករាយមួយដែលយើងបានកត់សម្គាល់ឃើញថា មួយរយៈចុងក្រោយនេះការរីករាលនៃជំងឺ កូវីដ-១៩ នៅក្នុងសហគមន៍ស្ថិតក្នុងកម្រិតទាបជាងមុន ហើយយើងពិតជាមានមោទនភាពយ៉ាងក្រៃលែងចំពោះការ ខិតខំប្រឹងប្រែងប្រកបដោយប្រសិទ្ធភាពរបស់ក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាលកម្ពុជា ស្របពេលជាមួយគ្នានោះ យើងក៏សូមកោតសរសើរយ៉ាងខ្លាំងចំពោះការខិតខំប្រឹងប្រែងរបស់ក្រុមការងារគ្រប់ជាន់ថ្នាក់របស់យើង ព្រមទាំងការគាំ ទ្រយ៉ាងខ្លាំងក្លាពីសំណាក់អតិថិជន សាធារណជន និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់របស់ ធនាគារ ហត្ថា ម.ក ក្នុងអំឡុង ពេលនៃការរីករាតត្បាតនៃជំងឺ។

ជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងទាំងនោះនិងដើម្បីកសាងវឌ្ឍនភាពប្រកបដោយស្ថិរភាពនៅក្នុងត្រីមាសទី ៣ ឆ្នាំ២០២១ ធនាគារ ហត្ថា ម.ក សម្រេចបាននូវកិច្ចការងារសំខាន់ៗមួយចំនួន និងបានធ្វើឱ្យកាន់តែប្រសើរឡើងនូវ ផលិតផល និងសេវាកម្មរបស់ខ្លួន រួមមាន៖១- ការបង្កើតការិយាល័យសម្រាប់អតិថិជនថៃ និងជប៉ុន ដើម្បីបម្រើអតិថិជន ដែលមានបំណងវិនិយោគនិងកំពុងវិនិយោគនៅកម្ពុជាឱ្យកាន់តែប្រសើរ ២- ដាក់ឱ្យដំណើរការនូវសេវាបើកគណនីជូន អតិថិជនដល់ទីកន្លែង ៣- ធ្វើឱ្យប្រសើរឡើងនូវសេវាធនាគារចល័ត Hattha Mobile ដែលអាចឱ្យអតិថិជនផ្ទេរប្រាក់ ដោយផ្ទាល់ទៅធនាគារផ្សេងទៀតដែលជាសមាជិកបាគង និងមុខងារជាច្រើនផ្សេងទៀត ៤- ដាក់ឱ្យដំណើរការសេវា ទូទាត់វិក្កយបត្រសម្រាប់ក្រុមហ៊ុនសំខាន់ៗ និងខេត្តមួយចំនួនបន្ថែមទៀត។

លើសពីនោះ ដើម្បីផ្តល់អត្ថប្រយោជន៍បន្ថែមដល់អតិថិជន ក៏ដូចជាលើកកម្ពស់កិត្តិនាមរបស់ខ្លួននៅលើទីផ្សារ ធនាគារ ហត្ថា ម.ក ក៏បានផ្តល់ជូននូវកម្មវិធីពិសេសជាច្រើន រួមមានដូចជា៖ ១- ការផ្តល់ជូនពិសេសសម្រាប់អ្នកលក់ អនឡាញ អ្នកលក់ហ្គាស និងអតិថិជនដែលទូទាត់ថ្លៃសេវានិងទំនិញខាងលើតាមរយៈ Hattha Mobile ២- ឥតគិតថ្លៃ ចំពោះការស្នើសុំលេខគណនីពិសេសដែលអាចជាលេខថ្ងៃខែឆ្នាំកំណើត លេខទូរសព្ទ ឬលេខពិសេសណាមួយដែល ងាយស្រួលចងចាំ ៣- ការផ្តល់ជូនកម្មវិធីពិសេសសម្រាប់អតិថិជនដែលទូទាត់ថ្លៃអគ្គិសនីតាម Hattha Mobile និង ៤- ការផ្តល់ជូនកម្មវិធីពិសេសសម្រាប់អតិថិជនដែលផ្ទេរប្រាក់តាម Hattha Mobile ក្នុងឱកាសពិធីបុណ្យភ្ជុំបិណ្ឌ។

ជាមួយនឹងទំនួលខុសត្រូវខ្ពស់ចំពោះសង្គមជាតិរបស់ខ្លួន ធនាគារ ហត្ថា ម.ក បានចូលរួម និងចែករំលែកទៅ កាន់ផ្នែកព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ តាមរយៈការបរិច្ចាគថវិកាមួយចំនួន និងបើកគណនីទៅកាន់វត្ត

សរុបជាង ១០០ វត្តនៅទូទាំងប្រទេស ដើម្បីសម្រួលដល់អតិថិជនក្នុងការចូលបច្ច័យ ឬធ្វើប្រតិបត្តិការសាច់ប្រាក់ពីគ្រប់ទិសទី ក្នុងអំឡុងពេលរាតត្បាតដោយសារជំងឺកូវីដ-១៩។ លើសពីនេះ ធនាគារ ហត្ថា ម.ក ក៏បានគាំទ្រយ៉ាងសកម្មក្នុងយុទ្ធនាការផ្សព្វផ្សាយរបស់សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) ទាក់ទងនឹងប្រសិទ្ធភាពនៃការគ្រប់គ្រងសាច់ប្រាក់ និងវិធានចាំបាច់នានាដើម្បីការពារ កូវីដ១៩ ដោយក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាលកម្ពុជា។

លើសពីនេះទៅទៀត ធនាគារ ហត្ថា ម.ក ក៏បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ជំហានបន្ទាប់របស់ខ្លួនដើម្បីផ្តល់ជូនអតិថិជននូវបទពិសោធន៍កាន់តែប្រសើរ តាមរយៈការធ្វើឱ្យកាន់តែប្រសើរឡើងនូវសេវាធនាគារចល័តរបស់ខ្លួន (UX / UI) ក៏ដូចជាសេវាហិរញ្ញវត្ថុជាច្រើនទៀតដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការជំរុញបន្ថែមដល់ភាពរីកចម្រើនរបស់ពួកគាត់ឱ្យកាន់តែឆាប់រហ័សផងដែរ។

## ផ្នែកទី ២ ៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក- លទ្ធផលប្រតិបត្តិការធុរកិច្ច

| លទ្ធផលសម្រេចបានសំខាន់ៗ | ផែនការ | លទ្ធផលសម្រេចបាន |
|---|---|---|
| ផ្នែកសេវាឥណទាន | | |
| ចំនួនគណនីសេវាឥណទាន | ១៨៩ ៥៧២ | ១៩៥ ២៩១ |
| ឥណទាននៅក្នុងដៃអតិថិជន (ពាន់ដុល្លារអាមេរិក) | ១ ៣៦៣ ៦៣៥ | ១ ៥២៤ ៨២២ |
| ផ្នែកសេវាប្រាក់បញ្ញើសន្សំ | | |
| ចំនួនគណនីសេវាប្រាក់បញ្ញើសន្សំ | ២៨៦ ២២៩ | ២៨៤ ១៦៩ |
| សមតុលប្រាក់បញ្ញើសន្សំ (ពាន់ដុល្លារអាមេរិក) | ៨២០ ១៧២ | ៨៦៥ ៦៣៧ |
| ផ្នែកសេវាកម្មផ្សេងៗទៀត | | |
| ចំនួនអ្នកប្រើប្រាស់កាតអេធីអឹម | ៨៦ ០៩៨ | ៦៧ ០២៨ |
| ចំនួនអ្នកប្រើប្រាស់សេវាធនាគារចល័ត | ៦៦ ២៦៤ | ៤៧ ២៨៣ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងខ្នាតតូច (ដុល្លារអាមេរិក) | ៤៦១ ០៩៩ | ១៩៦ ៦៣២ |
| ការណែនាំភ្ញៀវឱ្យប្រើប្រាស់សេវាធានារ៉ាប់រងអាយុជីវិតឥណទាន (ដុល្លារអាមេរិក) | ៦ ២១១ ៤១២ | ៨ ៣៨៦ ១៩៥ |
| ផ្នែកប្រតិបត្តិការសំខាន់ផ្សេងៗទៀត | | |
| ចំនួនការិយាល័យ | ១៧៧ | ១៧៧ |
| ចំនួនអេធីអឹម | ១៦២ | ១៣៧ |
| ចំនួនបុគ្គលិក | ៥ ៩២៣ | ៥ ៩៤១ |

ខ- រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី៣ ឆ្នាំ ២០២១ | | ត្រីមាសទី៣ ឆ្នាំ២០២០ | | ត្រីមាសទី៣ ឆ្នាំ ២០១៩ | |
|---|---|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ |
| ១ | ចំណូលការប្រាក់ | ២២៥ ៩៣១ | ៩៥,៧ | ១៧៤ ៩៧៦ | ៩៦,៣ | ១៤៩ ៤០៦ | ៩៦,១ |
| ២ | ចំណូលផ្សេងៗ | ១០ ១០៧ | ៤,៣ | ៦ ៦៤៣ | ៣,៧ | ៦ ០៤១ | ៣,៩ |
| ចំណូលសរុប | | ២៣៦ ០៣៨ | | ១៨១ ៦១៩ | | ១៥៥ ៤៤៧ | |

## ផ្នែកទី ៣ ៖ របាយការណ៍ហិរញ្ញវត្ថុដែលបានពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមពិនិត្យមើលរបាយការណ៍លម្អិតនៅក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ។

## ផ្នែកទី ៤ ៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ គឺជាការពិភាក្សាលើលទ្ធផលនៃប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុ ពីគណៈគ្រប់គ្រងរបស់ ធនាគារ ហត្ថា ម.ក ដោយផ្អែកទៅលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹម ថ្ងៃទី៣០ ខែ កញ្ញា ឆ្នាំ ២០២១ហើយដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ គិតត្រឹមថ្ងៃទី៣០ ខែ កញ្ញា ឆ្នាំ២០២១។

របាយការណ៍ហិរញ្ញវត្ថុទាំងនេះរបស់ធនាគារ ហត្ថា ម.ក ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

គណៈគ្រប់គ្រងធ្វើការពិភាក្សា និងវិភាគលើសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗដែលបាន ជះឥទ្ធិពលទៅលើប្រាក់ចំណេញរបស់ធនាគារ ហត្ថា ម.ក តែប៉ុណ្ណោះ ។

### ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

**ការវិភាគចំណូល**

ធនាគារ ហត្ថា ម.ក មានចំណូល ២ប្រភេទធំៗគឺ ចំណូលពីការប្រាក់ និងចំណូលផ្សេងៗ

| | |
|---|---|
| **ចំណូលពីការប្រាក់រួមមាន៖** ចំណូលការប្រាក់សុទ្ធដែលទទួលបានពីការផ្តល់ឥណទានដល់ អតិថិជន និងពីការដាក់ប្រាក់បញ្ញើនៅតាមបណ្តា ធនាគារនានា។ ហើយចំណូលទាំងនេះត្រូវទទួលស្គាល់ជាប្រចាំខែ។ | **ចំណូលផ្សេងៗរួមមាន៖** កម្រៃណែនាំសេវាធានារ៉ាប់រង កម្រៃផ្ទេរប្រាក់ ចំណូលកម្រៃផ្សេងៗ ចំណូលបានមកពីការប្រមូលឥណទានលុបចេញពីបញ្ជី ចំណេញពីការប្តូរប្រាក់ ។ល។ |

ចំណូលការប្រាក់ ជាចំណូលដ៏ធំនិងសំខាន់សម្រាប់ ធនាគារ ហត្ថា ម.ក ដែលមានរហូតដល់ ៩៥,៧% នៃចំណូលសរុប។

### ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១នេះ គណៈគ្រប់គ្រងរបស់ ធនាគារ ហត្ថា ម.ក យល់ថាផលប៉ះពាល់ជាអវិជ្ជមានការរីករាលដាលកូវីដ១៩ បានចាប់ផ្តើមមានភាពធូរស្បើយបន្តិចនៅក្នុងត្រីមាសនេះ ជាលទ្ធផលធ្វើឱ្យប្រាក់ចំណេញមានការកើនឡើងលើសពីត្រីមាសមុន។ លើសពីនេះទៅទៀត ធនាគារ ហត្ថា ម.ក បានប្រើប្រាស់ម៉ូឌែលផ្ទាល់ខ្លួនក្នុងការគណនាការខាតបង់ឥណទានដែលរំពឹងទុក (Estimated Credit Loss)។

### គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

នាដំណាច់ការិយបរិច្ឆេទថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១នេះ គណៈគ្រប់គ្រងរបស់ ធនាគារ ហត្ថា ម.ក យល់ថាការលក់ និងចំណូលមានការកើនឡើងនៅក្នុងដំណាក់កាលកូវីដ១៩នេះ។

### ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

ធនាគារ ហត្ថា ម.ក បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយប័ណ្ណគោលគឺ ប្រាក់ដុល្លារអាមេរិក។ ប្រតិបត្តិការជា រូបិយវត្ថុប្រាក់រៀល និងរូបិយប័ណ្ណប្រាក់ថៃបាត ត្រូវបានប្តូរទៅជា រូបិយប័ណ្ណគោលតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និង ខាតដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ ការប្តូរទ្រព្យសកម្មនិងបំណុល រូបិយប័ណ្ណបរទេស ត្រូវបានកត់ត្រា នៅក្នុងរបាយការណ៍លទ្ធផលលម្អិត។

**ង- ផលប៉ះពាល់នៃអតិផរណា**

ធនាគារ ហត្ថា **ម.ក** មិនបានកែប្រែអត្រាការប្រាក់ដោយផ្អែកតាមការប្រែប្រួលនៃអតិផរណាទេ ពោលគឺផ្អែកទៅលើស្ថានភាព ប្រកួតប្រជែងជាក់ស្តែងនៅក្នុងទីផ្សារ ហើយនៅតែរក្សាបាននូវចេរភាពហិរញ្ញវត្ថុយ៉ាងល្អប្រសើរ។

**ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល**

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២១ នេះ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជានៅតែបន្តអនុវត្តវិធានការដែលមានស្រាប់សំខាន់ៗជាច្រើនដើម្បីធានាឱ្យបាននូវកំណើន និងស្ថិរភាពសេដ្ឋកិច្ចជាតិ ដូចជាការបន្តផ្តល់ហិរញ្ញប្បទាន គាំទ្រនិយោជិតដែលត្រូវបានព្យួរការងារ (ក្នុងវិស័យកាត់ដេរ វាយនភណ្ឌ ស្បែកជើង និងទេសចរណ៍) និងគ្រួសារដែលមានប័ណ្ណក្រីក្រ ដើម្បីឆ្លើយតបទៅនឹងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការរីករាលដាលជំងឺកូវីដ១៩។
គោលនយោបាយពាក់ព័ន្ធទាំងនេះរួមមាន៖

នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១ ធនាគារជាតិនៃកម្ពុជា បានសម្រេចចិត្ត នៅក្នុងកិច្ចប្រជុំ គណៈកម្មាធិការគោលនយោបាយរូបិយវត្ថុរបស់ខ្លួន ក្នុងគោលដៅដើម្បី (១) បន្តរក្សាស្ថិរភាពអត្រាប្តូរប្រាក់ តាមរយៈការធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់តាមការចាំបាច់ (២) បន្តផ្តល់សន្ទនីយភាពជាប្រាក់រៀលតាមរយៈប្រតិបត្តិការ LPCO ដើម្បីឆ្លើយតបនឹងតម្រូវការសន្ទនីយភាពជាប្រាក់រៀលរយៈពេលខ្លីរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និង (៣) បន្តរក្សាអត្រាប្រាក់បម្រុងកាតព្វកិច្ច ក្នុងអត្រា ៧% ទាំងប្រាក់រៀល និងដុល្លារអាមេរិក។

បន្ថែមជាងនេះទៀត រាជរដ្ឋាភិបាលកម្ពុជា សម្រេចចិត្តបន្តសុពលភាពនៃវិធានការដែលបានដាក់ចេញនាពេលកន្លងមក ដើម្បីបន្តគាំទ្រដល់ប្រជាពលរដ្ឋ និងអាជីវកម្ម ដែលបាននឹងកំពុងរងផលប៉ះពាល់ពីជំងឺកូវីដ១៩។ គោលបំណងនៃការបន្តនេះ គឺការជួយគាំទ្រសង្គម/សេដ្ឋកិច្ច និងការការពារពីការរីករាលដាលជំងឺកូវីដ១៩ក្នុងសហគមន៍កម្រិតធំ ការបន្តរាល់កម្មវិធីទំនុកបម្រុងដែលមានស្រាប់ ការជួយគាំពារឱ្យអាជីវកម្មទាំងឡាយអាចសម្របខ្លួនទៅតាមស្ថានភាព "ប្រក្រតីភាពតាមគន្លងថ្មី" និងការបន្តរាល់កម្មវិធីជួយទំនុកបម្រុងផ្នែកហិរញ្ញវត្ថុដល់គ្រួសារក្រីក្រ និងប្រជាជនដែលរងផលប៉ះពាល់ពីជំងឺកូវីដ១៩។

**ហត្ថលេខារបស់អភិបាល ធនាគារ ហត្ថា ម.ក**

កាលបរិច្ឆេទ៖ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០២១
បានអាន និងឯកភាព

លោក ឡុញ ហៃ
អភិបាលឯករាជ្យ

កាលបរិច្ឆេទ៖ ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ២០២១
បានអាន និងឯកភាព

លោកបណ្ឌិត ឌី ដាវុឌ្ឍ
អភិបាលឯករាជ្យ

Hattha Bank

Subsidiary of krungsri bank

A member of MUFG, a global financial group